# អំពីជំងឺរលាកថ្លើម

| | ជំងឺរលាកថ្លើមជំពូកអេ (HAV) | ជំងឺរលាកថ្លើមជំពូកប៊ី (HBV) | ជំងឺរលាកថ្លើមជំពូកស៊ី (HCV) | ជំងឺរលាកថ្លើមជំពូកឌី (HDV) | ជំងឺរលាកថ្លើមជំពូកអ៊ី (HEV) |
|---|---|---|---|---|---|
| តើជម្ងឺរលាកថ្លើមជាអ្វី? | HAV គឺជាវីរុស (virus) ធ្វើឲ្យថ្លើមរលាក មិនបណ្តាលឲ្យទៅជាជំងឺរ៉ាំរ៉ៃទេ។ | HBV គឺជាវីរុសធ្វើឲ្យកើតរោគ រលាកថ្លើម។ វាអាចធ្វើឲ្យកោសិការបស់ថ្លើមខូច ហើយបណ្តាលឲ្យក្លាយជាថ្លើមរឹងនិងជំងឺមហារីក។ | HCV គឺជាវីរុសធ្វើឲ្យកើតរោគរលាកថ្លើម។ វាអាចធ្វើឲ្យកោសិការបស់ថ្លើមខូចខាត ហើយបណ្តាលឲ្យក្លាយជាថ្លើមរឹង និងជំងឺមហារីក។ | HDV គឺជាវីរុសធ្វើឲ្យថ្លើមរលាក។ វីរុសនេះ វាមានឥទ្ធិពលតែចំពោះអ្នកមាន HBV ។ | HEV គឺជាវីរុសធ្វើឲ្យកើតរោគរលាកថ្លើម។ វាមិនសូវកើតមាននៅសហរដ្ឋអាមេរិកទេ ហើយក៏មិនមានលក្ខណៈរ៉ាំរ៉ៃដែរ។ |
| កំឡុងពេលដែលជំងឺមិនទាន់ចេញមុខ | ២ទៅ៧សប្តាហ៍<br>ជាមធ្យមៈ ៤សប្តាហ៍ | ៦ទៅ២៣សប្តាហ៍<br>ជាមធ្យមៈ ១៧សប្តាហ៍ | ២ទៅ២៥សប្តាហ៍<br>ជាមធ្យមៈ ៧ទៅ៩សប្តាហ៍ | ២ទៅ៨សប្តាហ៍ | ២ទៅ៩សប្តាហ៍<br>ជាមធ្យមៈ ៤០ថ្ងៃ |
| តើវាឆ្លងដោយរបៀបណា? | ឆ្លងតាមលាមកនិងមាត់ (ការរួមភេទដោយប្រើមាត់) ការប៉ះពាល់គ្នា ឬទទួលទានអាហារនិងទឹកមានមេរោគនោះ។ ដៃប្រឡាក់លាមកដូចជាការប្តូរកន្ទបក្មូន អាច ឆ្លងពីដៃចូលមាត់បាន។ | ប៉ះនឹងឈាម និងទឹកកាមដែលមានមេរោគ ហើយនិងម្ជុល និងគ្រឿងប្រដាប់ចោះរាងកាយដែលមានប្រឡាក់មេរោគ។ ពីម្តាយមានរោគទៅទារក មនុស្សខាំ និងការរួមភេទ។ | ប៉ះនឹងឈាម ម្ជុលចាក់ ឡាម និងប្រដាប់ប្រដារសំរាប់ចោះឬសាក់ខ្លួនដែលបានប្រឡាក់មេរោគ។ ពីម្តាយមានរោគទៅទារក។ មិនសូវងាយឆ្លងដោយការរួមភេទទេ។ | ប៉ះនឹងឈាម និងម្ជុលដែលបានប្រឡាក់មេរោគ។ ការរួមភេទជាមួយអ្នកដែលមាន HDV។ | ឆ្លងដោយការប៉ះពាល់នឹងលាមកចូលទៅមាត់។ មនុស្សជាច្រើននៅប្រទេសផ្សេងៗកើតមានរោគនេះក្នុងពេលតែមួយដោយព្រោះតែនៅក្នុងទឹកមានមេរោគនោះ។ |
| រោគសញ្ញា | អាចមិនមានរោគសញ្ញាទេ។ អ្នកខ្លះអាចមានលាមកពណ៌ខ្ចី ទឹកនោមមានពណ៌មិនប្រក្រតី ការអស់កម្លាំង គ្រុនក្តៅ ដំណើរចង់ក្អួត ក្អួតចុកពោះ និងជម្ងឺខាន់លឿង។ | អាចមិនមានអាការរោគទេ។ អ្នកខ្លះអាចមានអាការរោគដូចគ្រុនផ្តាសសាយធំ ទឹកនោមមានពណ៌មិនប្រក្រតី លាមកពណ៌ខ្ចី ជម្ងឺខាន់លឿង ហត់អស់កម្លាំង និងគ្រុនក្តៅ។ | ដូច HBV | ដូច HBV | ដូច HBV |
| វិធីព្យាបាលជម្ងឺរ៉ាំរ៉ៃ | មិនមានវិធីព្យាបាលទេ។ | ប្រើថ្នាំ Interferon និងLamivudine. វិធីព្យាបាលនេះ មានជោគជ័យប្លែកៗពីគ្នា។ | ប្រើថ្នាំ Interferon ផ្សំជាមួយនឹងថ្នាំផ្សេងទៀតគ្នា។ មានជោគជ័យប្លែកៗពីគ្នា។ | ប្រើថ្នាំ Interferon . វិធីព្យាបាលនេះ មានជោគជ័យប្លែកៗពីគ្នា។ | មិនមានវិធីព្យាបាលទេ។ |
| ចាក់ថ្នាំបង្ការរោគ | សំរាប់អ្នកដែលមានអាយុចាប់ពីពីរឆ្នាំឡើងទៅត្រូវចាក់ពីរម្ជុល។ | សំរាប់មនុស្សគ្រប់វ័យ ត្រូវចាក់បីម្ជុល។ | មិនមានថ្នាំចាក់ការពារទេ។ | ការចាក់ថ្នាំការពារ HBV បង្ការមិនឲ្យមានជំងឺថ្លើម HDV ។ | មិនមានថ្នាំចាក់ការពារទេ។ |
| តើនរណាអាចមាន | វត្ថុប្រើប្រាស់ មនុស្សក្នុងផ្ទះ ឬការរួមភេទជា | ទារកកើតពីម្តាយដែលមានរោគនេះ ការរួម | អ្នកដែលបានបញ្ចូលឈាមមុន | អ្នកប្រើគ្រឿងញៀនដោយចាក់ | អ្នកធ្វើដំណើរទៅប្រទេសដែលកំ |

| | | | | | |
|---|---|---|---|---|---|
| គ្រោះថ្នាក់ដោយសាររោគនេះ? | មួយអ្នកដែលមានរោគ ឬក៏រស់នៅតំបន់កំពុងតែកើតមានជម្ងឺ HAV ។ អ្នកធ្វើដំណើរទៅប្រទេសដែលកំពុងអភិវឌ្ឍ អ្នកដែលរួមភេទតាមមាត់ និងប្រើថ្នាំញៀនដោយចាក់នឹងម្ជុល។ | ភេទជាមួយអ្នកកើតរោគនេះ ឬមានគូរច្រើន អ្នកប្រើគ្រឿងញៀនដោយចាក់នឹងម្ជុល អ្នកជួយសង្គ្រោះការអាសន្ន បុគ្គលិកផ្នែកសុខភាព អ្នករួមភេទដោយប្រើមាត់ និងអ្នកជំងឺដែលប្រើម៉ាស៊ីនសំរាប់លាងឈាម។ | ឆ្នាំ១៩៩២ បុគ្គលិកផ្នែកសុខភាព អ្នកប្រើគ្រឿងញៀនដោយចាក់នឹងម្ជុល អ្នកជម្ងឺដែលប្រើម៉ាស៊ីនសំរាប់លាងឈាម ទារកកើតពីម្តាយដែលមានរោគនេះ ការរួមភេទជាមួយគូរច្រើន។ | នឹងម្ជុល អ្នករួមភេទដោយប្រើមាត់ និងអ្នករួមភេទជាមួយអ្នកមាន HDV។ | ពុងធ្វើការអភិវឌ្ឍន៍ ជាពិសេសស្ត្រីដែលមានផ្ទៃពោះ។ |
| ការបង្ការរោគ | ត្រូវប្រើថ្នាំ Immune Globulin ក្នុងរយៈពេល២អាទិត្យបន្ទាប់ពីបានប៉ះនឹងមេរោគនេះ។ ការចាក់ថ្នាំការពារ។ លាងដៃនឹងសាប៊ូនិងទឹកបន្ទាប់ពីប្រើបង្គន់ហើយ។ ប្រើទឹកbleach (ទឹក១០ភាគលាយនឹងbleach មួយភាគ) ដើម្បីលាងសំអាតកន្លែងដែលប្រឡាក់នឹងលាមកដូចជាតុប្តូរកន្ទបក្មួនក្មេង។ ប្រើវិធីការពារនៅពេលរួមភេទ។ | ត្រូវប្រើថ្នាំ Immune Globulin ក្នុងរយៈពេល២អាទិត្យបន្ទាប់ពីបានប៉ះនឹងមេរោគនេះ។ ការចាក់ថ្នាំការពារអាចជួយការពារបានដល់ទៅ១៨ឆ្នាំ ឬក៏ច្រើនទៀត។ ប្រើទឹកbleach លាងកន្លែងដែលមានប្រឡាក់ឈាមមានមេរោគ និងពាក់ស្រោមដៃការពា។ សូមកុំប្រើឡាមកោរ ច្រាសដុសធ្មេញ ឬម្ជុលរួមគ្នា។ ប្រើវិធីការពារនៅពេលរួមភេទ។ | ប្រើទឹកbleach លាងកន្លែងមានប្រឡាក់ឈាមដែលកំពប់។ ពាក់ស្រោមដៃការពារនៅពេលដែលប៉ះពាល់ឈាម។ សូមកុំប្រើឡាមកោរ ច្រាសដុសធ្មេញ ឬម្ជុលរួមគ្នា។ ប្រើវិធីការពារនៅពេលរួមភេទ។ | ចាក់ថ្នាំការពារដើម្បីបង្ការដំបៅរលាកដោយ HBV ។ ប្រើវិធីការពារនៅពេលរួមភេទ។ | ជៀសវាងកុំទទួលទាន ឬប្រើទឹកដែលអាចមានមេរោគ។ |